# ជំពូកទី ១
# សេចក្តីផ្តើម

Draft

Draft

# ជំពូកទី១

## សេចក្តីផ្តើម

១. ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតាមបណ្តាប្រទេសមួយចំនួននៅលើពិភពលោក ក្នុងដំណាក់កាលដំបូងជានិច្ចជាកាលតែងតែប៉ះពាល់លើធនធានធម្មជាតិ ដែលជាប្រភពធនធានដ៏សំខាន់សំរាប់ទ្រទ្រង់ជីវិតសត្វលោក។ ដោយឡែកសំរាប់ប្រទេសកម្ពុជា ក៏បានចាប់ផ្តើមលើការធ្វើអាជីវកម្ម ធនធានព្រៃឈើតាមរយៈរូបភាពដីសម្បទាន និងការកាប់រានពង្រីកដីធ្វើកសិកម្មជាបន្តបន្ទាប់។ ការពង្រីកដីដើម្បីដាំដំណាំកសិកម្ម និងដំណាំឧស្សាហកម្មនេះត្រូវបានអនុវត្តតាមរូបភាពពីរយ៉ាងគឺ: (១) តាមរូបភាពក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និង (២) តាមរូបភាពចំការដំណាំគ្រួសារ។

២. ទោះបីជាព្រៃសម្បទាននៅទូទាំងប្រទេស បានលុបចោលស្ទើរតែទាំងស្រុងជាយូរមកហើយក្តី តែគំរបព្រៃ និងដំណុះឡើងវិញរបស់ព្រៃពុំមានលក្ខណៈប្រសើរឡើងទេ។ ក្នុងខណៈដែលច្បាប់ និងសារាចរជាច្រើនបានបង្កើតឡើងក្នុងគោលបំណងធ្វើយ៉ាងណា ដើម្បីធានាបាននូវចីរភាពបរិស្ថាន ប៉ុន្តែជាក់ស្តែងយើងគួរតែហ៊ានទទួលស្គាល់ថា យន្តការនៃការអនុវត្តន៍ទាំងឡាយនោះនៅពុំទាន់មានប្រសិទ្ធិភាពគ្រប់គ្រាន់ ដើម្បីទប់ស្កាត់សកម្មភាពលួចឆ្មក់ពីសំណាក់ជនឱកាសនិយម និងតំរូវការដើម្បីការរស់នៅរបស់សហគមន៍មូលដ្ឋានបានឡើយ។ ហើយអ្វីដែលជាកង្វល់ គឺធនធានព្រៃឈើទាំងនោះបាននឹងកំពុងតែបន្តបាត់បង់ទៅដោយទាំងពុំបានផ្តល់ចំណូលដល់ថវិកាជាតិ ចំណែកឯសហគមន៍មូលដ្ឋានខ្លួនឯងក៏កាន់តែក្រីក្រទៅៗ ដោយការប្រឈមមុខជាមួយនឹងអន្តរកម្មរវាងភាពក្រីក្រ និងការរេចរឹលផ្នែកបរិស្ថាន និងភាពព្រងើយកន្តើយមិនអើពើចំពោះភាពចាំបាច់ផ្នែកសេដ្ឋកិច្ច ដែលជាលទ្ធផលអាចនាំឱ្យឈានទៅដល់ស្ថានភាពអូសបន្លាយមួយ ក្នុងនោះសហគមន៍ទាំងឡាយ នោះអាចនឹងបំផ្លាញ ឬធ្វើឱ្យខ្សោះដោយអចេតនានូវធនធានដ៏ផុយស្រួយ ដែលពួកគាត់កំពុងតែពឹងផ្អែកប្រាស្រ័យ សម្រាប់ការរស់នៅរបស់ពួកគាត់។

៣. ជាមួយនឹងអន្តរកម្មរវាងភាពក្រីក្រ និងការរេចរិលផ្នែកបរិស្ថាននេះ វាបាននឹងកំពុងតែធ្វើឱ្យល្បឿននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចថយចុះយ៉ាងស្ងប់ស្ងាត់ ដោយសារតម្រូវឱ្យមានការបង្កើនខ្ទង់ថវិកា នៃផ្ទាំសារពើពន្ធទៅលើកម្មវិធីសេវាកម្មសុខាភិបាល ការស្តារឡើងវិញនូវការធ្លាក់ចុះនៃផលិតភាពកសិកម្ម និងការស្តារឡើងវិញនូវធនធានធម្មជាតិផងដែរ។

៤. ជាការពិតណាស់ដែលថាសកម្មភាពអភិវឌ្ឍន៍ទាំងនេះ ទោះតិចក្តីច្រើនក្តី តែងតែប៉ះពាល់លើធនធានធម្មជាតិ និងជីវភាពរស់នៅរបស់ប្រជាជនក្នុងសហគមន៍មូលដ្ឋាន ដូច្នេះហើយទើបគំរោងអភិវឌ្ឍន៍ទាំងនេះ ត្រូវបានយកចិត្តទុកដាក់ឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានឱ្យបានច្បាស់លាស់។

៥. នៅក្នុងស្ថានភាពដែលយើងកំពុងតែដឹង និងមើលឃើញថា ធនធានព្រៃឈើកាន់តែរេចរិល ខ្សត់ទៅៗ ដោយសារចរន្តនៃការចំរាញ់យកផលពីសំណាក់ជនឱកាសនិយម និងការបន្តនូវប្រពៃណីផ្តេកផ្តួលរបស់ប្រជាជនសហគមន៍ទៅលើធនធានទាំងនោះ យើងគួរតែបង្វែរចក្ខុវិស័យទៅលើវិធីសាស្ត្រ ប្រសិទ្ធិភាព

នៃការប្រើប្រាស់ដីនៅក្នុងជម្រើសផ្សេងទៀត តាមរយៈការប្រែក្លាយតំបន់ព្រៃរេចរិល ឬព្រៃដែលមានតំលៃពាណិជ្ជកម្មទាប ទៅជាតំបន់អភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម ជាមួយនឹងការរៀបចំផែនការប្រើប្រាស់ និងគ្រប់គ្រងដីឱ្យបានសមស្រប ដោយផ្សារភ្ជាប់ជាមួយនឹងវិធានការគ្រប់គ្រងបរិស្ថាន ក្នុងនោះការកាត់បន្ថយក្នុងកំរិតអតិបរមានូវហេតុប៉ះពាល់អវិជ្ជមានទៅលើបរិស្ថានរយៈពេលខ្លី និងវែង ហើយនិងការយកចិត្តទុកដាក់ចំពោះបញ្ហាសហគមន៍នៅក្នុងក្របខ័ណ្ឌមួយដែលមានតម្លាភាព និងគណនីយភាពត្រឹមត្រូវច្បាស់លាស់ នោះវានឹងនាំមកនូវប្រសិទ្ធិភាពសេដ្ឋកិច្ចខ្លាំងថែមទៀតជាក់ជាមិនខាន។

៦. ជាការពិតណាស់ដែលថា នៅពេលដែលយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍បានប្រែក្លាយតំបន់មួយទៅជាតំបន់កសិ-ឧស្សាហកម្មហើយនោះ អ្វីដែលជាអត្ថប្រយោជន៍សំរាប់ប្រជាជនមូលដ្ឋានគឺការនាំមកនូវវិបុលភាពជាក់លាក់មួយនៅក្នុងសង្គមជនបទ។ ព្រោះថា នៅពេលដែលឱកាសនៃការផ្តល់ការងារដល់កម្មករមានសន្ទុះកើនឡើង កំរិតនៃផលចំណូលគ្រួសារក៏មានលក្ខណៈល្អប្រសើរទៅតាមនោះដែរ។ ជាលទ្ធផលកំណើននៃលទ្ធភាពទិញដូរនឹងជំរុញឱ្យសកម្មនូវចរន្តសេដ្ឋកិច្ចនៅក្នុងតំបន់ តាមរយៈការបំពេញសេចក្តីត្រូវការទំនិញ និងសេវាកម្មផ្សេងៗរបស់សហគមន៍។

៧. ក្នុងពេលដែលសង្គម និងបរិស្ថានមានការផ្លាស់ប្តូរស្របគ្នាជាមួយនឹងដំណើរការនៃការអភិវឌ្ឍន៍ជាវិជ្ជមាននោះ ក៏អាចបណ្តាលឱ្យមាននូវជម្លោះផ្សេងៗផងដែរ។ ដូច្នេះដើម្បីសំរេចបាននូវឆន្ទៈនយោបាយក្នុងការអភិវឌ្ឍន៍ដំណាំកសិកម្ម និងដំណាំកសិ-ឧស្សាហកម្មមួយគឺ ផ្អែកលើទស្សនទានសង្គម-បរិស្ថាន និងសេដ្ឋកិច្ចការរៀបចំនូវឯកសារបទដ្ឋានបច្ចេកទេស (ផែនការពិស្តារ និងផែនការប្រតិបត្តិប្រចាំឆ្នាំនីមួយៗ ការគណនាអំ។ីភាពស្ថិតស្ថេរផ្អែកសេដ្ឋកិច្ច របាយការណ៍វាយតំលៃ អំពីហេតុប៉ះពាល់បរិស្ថាននិងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន) គឺជាចំណុចគន្លឹះសំរាប់ក្រុមការងារអន្តរស្ថាប័នពាក់ព័ន្ធ ប្រើជាឧបករណ៍សំរាប់ធ្វើការតាមដានត្រួតពិនិត្យ-វាយតំលៃទៅលើរាល់សកម្មភាព និងសុច្ចនាករនានា ដែលអាចធានាបានថារាល់សកម្មភាពនៃការអភិវឌ្ឍន៍គំរោង ពិតជាឆ្លើយតបទៅនឹងទស្សនទានសង្គម-បរិស្ថាន និងសេដ្ឋកិច្ច។

៨. យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល បានផ្តល់អាទិភាពខ្ពស់ដល់ការលើកស្ទួយវិស័យកសិកម្មក្នុងចំណោមវិស័យសំខាន់ៗផ្សេងទៀត ដើម្បីជំរុញការអភិវឌ្ឍន៍ប្រទេស ដោយសំអាងទៅលើសក្តានុពលផ្អែកគោលនយោបាយដែលមានភាពអនុគ្រោះ លក្ខណៈភូមិសាស្ត្រនិងអាកាសធាតុដែលអំណោយផលល្អ និងធនធានដីទំនេរដែលសម្បូណ៌ដីជាតិ អាចដាំដុះដំណាំច្រើនមុខ ជាពិសេសដំណាំកសិ-ឧស្សាហកម្មដូចជាដំណាំកៅស៊ូជាដើម ដើម្បីផលិតជ័រកៅស៊ូសម្រាប់តម្រូវការក្នុងស្រុក និងលក់ចេញទៅលើទីផ្សារអន្តរជាតិ។ ដើម្បីឲ្យការលើកស្ទួយវិស័យកសិកម្មនេះសម្រេចបានជោគជ័យ យុទ្ធសាស្ត្រទាក់ទាញក្រុមហ៊ុនវិនិយោគជាតិ និងអន្តរជាតិរបស់រាជរដ្ឋាភិបាល ក៏បានដើរតួនាទីសំខាន់ក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងជំរុញឲ្យមានកំណើនសេដ្ឋកិច្ចជាតិ តាមរយៈក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ច ក្នុងការអភិវឌ្ឍន៍ជនបទមូលដ្ឋាន ការអភិវឌ្ឍន៍សេវាកម្មសាធារណៈ (ផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព ថាមពលអគ្គិសនី ទឹកស្អាត...) ការផ្តល់កាលានុវត្តភាពការងារ និងធ្វើឲ្យមានចរន្តសេដ្ឋកិច្ចនៅក្នុងតំបន់។

Draft

៩. ដោយមើលឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេសជាតិរបស់រាជរដ្ឋាភិបាល និងដើម្បីចូលរួមចំណែកជួយរាជរដ្ឋាភិបាលសម្រេចបាននូវទិសដៅដែលបានដាក់ចេញ ហើយដោយមានការគាំទ្រពីគណៈនៃគណៈអភិបាលខេត្តក្រចេះផងនោះ ក្រុមហ៊ុន **ដូទីសាយហ្គុន-ប៊ិញហឿក (អេស ប៊ី ខេ)** បានស្នើសុំដីសម្បទានសេដ្ឋកិច្ច ពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈឯកឧត្តមអភិបាលខេត្តក្រចេះ និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ លើទំហំផ្ទៃដីជាក់ស្តែងចំនួន ៥.៤៣៦ហិកតា ស្ថិតក្នុងភូមិសាស្ត្រឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) ដោយផ្អែកទៅលើទីតាំងភូមិសាស្ត្រ អាកាសធាតុ ស្ថានភាពដី ដែលមានលក្ខណៈអំណោយផលដល់ដំណាំកៅស៊ូ ស្របពេលដែលផលិតផលជ័រកៅស៊ូកំពុងមានតម្រូវការកើនឡើងជាលំដាប់នៅលើទីផ្សារក្នុងស្រុក និងអន្តរជាតិ។

## ១-១ គោលបំណង

**១០.** គោលបំណងនៃការវិនិយោគអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) របស់ក្រុមហ៊ុន **ដូទីសាយហ្គុន-ប៊ិញហឿក (អេស ប៊ី ខេ)** គឺសំដៅចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្មប្រកបដោយនិរន្តរភាព និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាតាមរយៈការវិនិយោគ ស្តារ អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បង្កើនប្រាក់ចំណូលគ្រួសារប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់វិនិយោគ និងបង្កើនផលិតកម្មកសិកម្ម ដោយការអភិវឌ្ឍន៍ចំការកៅស៊ូ បង្កើតផលិតភាពកៅស៊ូលើផ្ទៃដីព្រៃដែលត្រូវកាប់បំផ្លាញរេចរឹលប្រែក្លាយដំណាំកៅស៊ូ ឲ្យមានតួនាទីសំខាន់ក្នុងការជំនួសគម្របព្រៃឈើដែលបាត់បង់ដោយការកាប់បំផ្លាញអនាធិបតេយ្យកន្លងមក សំដៅបង្កើតឲ្យមានគម្របព្រៃការពារលំនឹងបរិស្ថានធម្មជាតិឡើងវិញផង និងផ្តល់នូវផលិតផលកៅស៊ូដែលមានតម្រូវការខ្ពស់នៅលើទីផ្សារអន្តរជាតិផង។ តែទោះជាយ៉ាងនេះក្តី ព្រៃឈើដែលរេចរឹលទាំងនោះក៏មានតួនាទីជាអ្នករក្សាសុវត្ថិភាពដល់ភាវៈទូទៅរបស់អេកូឡូស៊ីបរិស្ថាន និងសង្គមផងដែរ នៅពេលដែលយើងគ្រប់គ្រងបានត្រឹមត្រូវ។ ដូច្នេះគោលបំណងនៃការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ សម្រាប់គម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូនេះគឺ កំណត់ ព្យាករណ៍ និងវាយតម្លៃអំពីសក្តានុពលផលប៉ះពាល់បរិស្ថានសមស្របមួយ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមាន។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ការសិក្សាវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញត្រូវបានយកចិត្តទុកដាក់សំខាន់ទៅលើបញ្ហាមួយចំនួនដូចខាងក្រោម៖

- កំណត់ស្ថានភាពបរិស្ថានធម្មជាតិដែលមានស្រាប់ (ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសង្គម)
- ធ្វើការវាយតម្លៃឡើងវិញអំពីស្ថានភាពសេដ្ឋកិច្ចសង្គមនៅក្នុងសហគមន៍ ដែលប្រឈមនឹងការទទួលរងឥទ្ធិពលអាក្រក់ពីសកម្មភាពគម្រោងអភិវឌ្ឍន៍។
- កំណត់អំពីបញ្ហានៃការប្រើប្រាស់ដីធ្លីក្នុងពេលបច្ចុប្បន្ន និងផ្តល់អនុសាសន៍សម្រាប់ជំរុញដំណើរការចុះបញ្ជីដីធ្លីជាស្ថាពរ។
- រៀបចំផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍។

Draft

- រៀបចំផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ សម្រាប់រៀបចំកម្មវិធីស្តារគុណភាពបរិស្ថាន (Environmental Development Program)។
- កំណត់សក្តានុពលផលប៉ះពាល់អវិជ្ជមានទៅលើគុណភាពបរិស្ថាន (បរិយាកាស ទឹក និងដី) និងផ្តល់នូវវិធានការកាត់បន្ថយ។
- កំណត់សក្តានុពលផលប៉ះពាល់អវិជ្ជមានទៅលើសេដ្ឋកិច្ចសង្គម និងផ្តល់នូវវិធានការកាត់បន្ថយ។
- រៀបចំផែនការគ្រប់គ្រងបរិស្ថាន.និងផែនការកាត់បន្ថយផលប៉ះពាល់សង្គម។
- ធ្វើវិភាគ និងវាយតម្លៃសេដ្ឋកិច្ចបរិស្ថាន និងសង្គមរបស់គម្រោង។
- រៀបចំកម្មវិធីត្រួតពិនិត្យ និងវាយតម្លៃបរិស្ថាន និងសង្គមសម្រាប់គម្រោងនេះ។

## ១.២ វិធីសាស្ត្រ និងទំហំនៃការសិក្សា

១០. វិធីសាស្ត្រក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញសម្រាប់គម្រោងនេះ (មានពិពណ៌នាពិស្តារនៅក្នុងជំពូកទី២) មានចំណុចគោលសំខាន់ៗមួយចំនួន ដូចជា៖

- ការសិក្សាអំពីធនធានបរិស្ថានធម្មជាតិ និងសង្គមដែលមានស្រាប់នៅក្នុងតំបន់គម្រោង ដោយផ្តោតសំខាន់ទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម។ ទិន្នន័យសម្រាប់ការសិក្សានេះ ត្រូវបានប្រមូលតាមវិធីសាស្ត្រសំខាន់ៗចំនួនពីរ គឺ៖
  - **ការប្រមូលទិន្នន័យនិងព័ត៌មានបឋម៖** ទិន្នន័យពាក់ព័ន្ធនឹងធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គមដែលធ្លាប់បានសិក្សាពីមុនមក ត្រូវបានយកមកប្រើប្រាស់ជាឯកសារជំនួយសិក្សា មានដូចជា៖
    - ផែនទី (ទិន្នន័យរដ្ឋបាលព្រៃឈើ GIS & RS Datasets, 2010)៖ ផែនទីរយៈកម្ពស់, ផែនទីភូគព្ភសាស្ត្រ, ផែនទីឋានលេខា, ផែនទីចំណាត់ថ្នាក់ប្រភេទដី, ផែនទីចំណាត់ថ្នាក់ទីជម្រាល, ផែនទីប្រព័ន្ធផ្លូវទឹក, ផែនទីប្រើប្រាស់ដីក្នុងពេលបច្ចុប្បន្ន។
    - ទិន្នន័យជីវរូបសាស្ត្រ (Bio-physical Data) ពីក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ខេត្តក្រចេះ (ឆ្នាំ២០០៤-២០១៣)។
    - ឯកសារជំរឿនប្រជាសាស្ត្រទូទៅឆ្នាំ២០០៨, ការអង្កេតអំពីសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៩, ២០១០, របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង, ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៤។
  - ការប្រមូលទិន្នន័យនិងព័ត៌មានដែលត្រូវសិក្សា៖
    - ធនធានរូបសាស្ត្រ៖ គុណភាពខ្យល់, សម្លេង និងរំញ័រ, វិភាគគុណភាពទឹកក្រោមដី, វិភាគគុណភាពទឹកលើដី, វិភាគគុណភាពដី។
    - ធនធានជីវសាស្ត្រ៖



Draft

- ✓ រុក្ខអេកូឡូស៊ីៈ ស្ថានភាពព្រៃក្នុងតំបន់សិក្សា, សារពើន្ធរុក្ខជាតិក្នុងតំបន់សិក្សា, ប្រភេទឈើត្រូវបានការពារដោយច្បាប់, ដង់ស៊ីតេ និងមាឌឈើ ដោយការរៀបចំឡូត៍-អនុឡូត៍គម្រូ និងប្រើប្រាស់ផែនទី (ទិន្នន័យរដ្ឋបាលព្រៃឈើ GIS & RS Datasets, 2010) មានដូចជា ផែនទីគម្របព្រៃឆ្នាំ២០០២, ផែនទីគម្របព្រៃឆ្នាំ២០០៦, ផែនទីគម្របព្រៃឆ្នាំ២០១០, ផែនទីរបៀងសត្វព្រៃ។
- ✓ សត្វអេកូឡូស៊ី (សត្វស្លាប, ថនិកសត្វ)
- ✓ មច្ឆជាតិ

- ○ ធនធានសេដ្ឋកិច្ច-សង្គមៈ ស្ថានភាពភូមិសាស្ត្រ, ស្ថានភាពប្រជាសាស្ត្រ, ផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារ, ការប្រើប្រាស់ទឹកនិងថាមពល, ការគ្រប់គ្រង និងការកាន់កាប់ដីធ្លី, លទ្ធភាពអាស្រ័យផលពីធនធានធម្មជាតិ, ប្រភពចំណូលសំខាន់របស់គ្រួសារ, សេវាសាធារណៈ, ព័ត៌មានអំពីក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ដីសម្បទាន, ស្ថានភាពចំណាក-ចំណូលស្រុក, សម្បត្តិវប្បធម៌ ទំនៀមទំលាប់ប្រពៃណី, ទស្សនៈរបស់ប្រជាពលរដ្ឋចំពោះដីសម្បទានសេដ្ឋកិច្ច និងសំណូមពរ តាមរយៈការធ្វើសម្ភាសន៍, ការប្រជុំពិគ្រោះយោបល់ជាក្រុម (FGD), សិក្ខាសាលាពិគ្រោះយោបល់ និងការវិភាគដោយកម្មវិធី SPSS។

- ▪ ការវិភាគអំពីតម្លៃបរិស្ថាន-សេដ្ឋកិច្ច និងសង្គមៈ វិភាគការខូចខាតតម្លៃបរិស្ថាន-សេដ្ឋកិច្ចសង្គមដោយសារសកម្មភាពគម្រោង និងវិភាគអំពីតម្លៃសេដ្ឋកិច្ចគម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូ។
- ▪ ការវិភាគអំពីហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ ក្នុងដំណាក់កាលមុនប្រតិបត្តិ, ពេលប្រតិបត្តិ និងក្រោយប្រតិបត្តិ។

## ១.៣ ការរៀបចំរបាយការណ៍

១១. ការរៀបចំរបាយការណ៍ត្រូវបានរៀបចំឡើង អនុលោមទៅតាមខ្លឹមសារនៃគោលការណ៍ទូទៅ នៅក្នុងឧបសម្ព័ន្ធទី១នៃប្រកាសលេខ ៣៧៦ ប្រក បស្ថ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ស្ដីពីគោលការណ៍ណែនាំទូទៅសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងបរិស្ថាន និងមានការកែប្រែខ្លះទៅតាមស្ថានភាព ជាក់ស្ដែងដែលពាក់ព័ន្ធនឹងគម្រោង។ ជារួម របាយការណ៍ត្រូវបានចងក្រងឡើង តាមទំរង់ដូចខាងក្រោមៈ

មូលន័យសង្ខេប
ជំពូកទី១ សេចក្ដីផ្ដើម
ជំពូកទី២ វិធីសាស្ត្រស្រាវជ្រាវ
ជំពូកទី៣ ក្របខណ្ឌច្បាប់ជាតិ
ជំពូកទី៤ ការពិពណ៌នាពីគម្រោង

ជំពូកទី៥ ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់
ជំពូកទី៦ ការចូលរួមពីសាធារណៈជន
ជំពូកទី៧ ហេតុប៉ះពាល់បរិស្ថាន និងសង្គម និងវិធានការកាត់បន្ថយ
ជំពូកទី៨ ផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប)
ជំពូកទី៩ វិភាគអំពីតម្លៃបរិស្ថាន-សេដ្ឋកិច្ច និងសង្គម
ជំពូកទី១០ សន្និដ្ឋាន និងអនុសាសន៍
ឧបសម្ព័ន្ធ

Draft